# លិខិតុបករណ៍ អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនរងគ្រោះ ពីការរំលោភបំពានសិទ្ធិមនុស្ស

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

*000000000024*

ចែកជូនដោយឥតគិតថ្លៃ

នេះគឺជាការបោះពុម្ពផ្សាយដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងឱកាសខួបលើកទី៦០នៃការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សកាលពីឆ្នាំ១៩៤៨ និងខួបលើកទី១៥ នៃការអនុម័តរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ១៩៩៣។

អង្គការសហប្រជាជាតិ

សិទ្ធិមនុស្ស

# លិខិតុបករណ៍អង្គការសហប្រជាជាតិ
# ស្តីពីសិទ្ធិជនរងគ្រោះ
# ពីការរំលោភបំពានសិទ្ធិមនុស្ស

## សេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌
## សំរាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច (១៩៨៥)

## គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបាន
## ការដោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះ
## ដោយការរំលោភបំពានដ៏ធំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ
## និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ (២០០៦)

បោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំនៅកម្ពុជា ខែកក្កដា ឆ្នាំ២០០៨

# លិខិតុបករណ៍អង្គការសហប្រជាជាតិ
# ស្តីពីសិទ្ធិជនរងគ្រោះ
# ពីការរំលោភបំពានសិទ្ធិមនុស្ស

**អារម្ភកថា**

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សតំកល់នៅក្នុង មាត្រា៨ ពីសិទ្ធិទទួលបានការដោះស្រាយមួយ ប្រកបដោយប្រសិទ្ធភាព ដល់ជនរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្ស ថាជាសិទ្ធិមនុស្សសារវន្ត។ បន្ទាប់មក សិទ្ធិនេះត្រូវបានដាក់បញ្ចូលក្នុង **កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត។ សន្ធិសញ្ញាសិទ្ធិមនុស្សទាំងនេះ ត្រូវបានដាក់បញ្ចូលក្នុងច្បាប់កម្ពុជា តាមរយៈមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។

នៅក្នុងប្រទេសជាច្រើន ការរំលោភបំពានសិទ្ធិមនុស្ស បង្កើតបានជាបទឧក្រិដ្ឋតាមច្បាប់ជាតិ ហើយអាស្រ័យហេតុនេះ ជន

រងគ្រោះពីការរំលោភបំពានត្រូវមានសិទ្ធិទទួលបានយុត្តិធម៌តាមរយៈ ការផ្តន្ទាទោសជនល្មើស ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ(នៃប្រទេសនោះ) ហើយជាយថាហេតុ ត្រូវទទួលបានសំណងព្យសនកម្ម។ ទោះបីយ៉ាងណាក៏ដោយ ប្រជាជនរាប់លាននាក់នៅលើពិភពលោក ទទួលរងអន្តរាយ ដោយសារតែឧក្រិដ្ឋកម្ម និងការរំលោភអំណាច ហើយសិទ្ធិរបស់ពួកគេជាជនរងគ្រោះ ជារឿយៗ នៅតែមិនទាន់ត្រូវបានទទួលស្គាល់ពេញលេញនៅឡើយ។ នៅឆ្នាំ១៩៨៥ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័ត **សេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ សំរាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច**។ សេចក្តីប្រកាសនេះ បង្កើតគោលការណ៍ជាមូលដ្ឋាននានា សំដៅជួយដល់រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីការពារយុត្តិធម៌ និងការជួយដល់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងជនរងគ្រោះពីការរំលោភអំណាច ដោយធានាថា ជនរងគ្រោះទាំងនេះ មានសិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបានបដិទាន និងសំណងជាប្រាក់។ សេចក្តីប្រកាសនេះ គ្របដណ្តប់លើជនរងគ្រោះទាំងពីរនៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច ដែលមានន័យថា "អំពើសកម្ម ឬអកម្មដែលមិនទាន់បានបង្កើតទៅជាការរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌជាតិនៅឡើយក្តី តែពិតជាបាន

រំលោភបំពានលើរិធានទាំងឡាយ ទាក់ទងនឹងសិទ្ធិមនុស្សដែលត្រូវ

បានទទួលស្គាល់ជាអន្តរជាតិ ។"

នៅពេលអនុម័តសេចក្តីប្រកាសនេះ មហាសន្និបាតបានស្នើសុំដល់រដ្ឋនានាឱ្យអនុវត្តផងដែរនូវៈ

- គោលនយោបាយបង្ការផ្នែកសង្គមកិច្ច សុខាភិបាល (រួមទាំងសុខភាពផ្លូវចិត្ត) អប់រំ សេដ្ឋកិច្ច និងគោលនយោបាយបង្ការឧក្រិដ្ឋកម្មជាក់ស្តែង ដើម្បីកាត់បន្ថយការធ្វើឱ្យមានជនរងគ្រោះ និងជំរុញការជួយគាំទ្រដល់ជនរងគ្រោះ ដែលទទួលរងការឈឺចាប់ខ្លាំង ។
- កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ និង ការចូលរួមជាសាធារណៈ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម ។
- ការត្រួតពិនិត្យច្បាប់និងការអនុវត្តន៍ដែលនៅជាធរមានអោយបានទៀងទាត់ ដើម្បីធានាពីការឆ្លើយតបជាវិជ្ជមាន ចំពោះកាលៈទេសៈប្រែប្រួល ។
- ការអនុម័ត និងការអនុវត្តន៍ច្បាប់ ដែលហាមប្រាមចំពោះអំពើ

នានា ដែលរំលោភបំពានវិធានទាំងឡាយ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ទាក់ទងនឹងសិទ្ធិមនុស្ស ក្រមសីលធមិសាជីវៈកម្ម និងការរំលោភអំណាចដទៃទៀត។

- ការបង្កើត និងការពង្រឹងមធ្យោបាយនានា នៃការស្វែងរកចាប់ខ្លួន ការចោទប្រកាន់ និងការផ្តន្ទាទោសជនណាដែលមានពិរុទ្ធភាពពីបទឧក្រិដ្ឋនានា។
- ការបង្ហាញព័ត៌មាន ពីក្រមសីលធមិរបស់មន្ត្រី និងសាជីវកម្មឱ្យបានទូលាយដើម្បីឱ្យសាធារណៈជនអាចពិនិត្យមើលបាន និងការបង្ហាញពីមធ្យោបាយដទៃទៀត នៃការឆ្លើយតបជាវិជ្ជមានបន្ថែមទៀត ចំពោះការព្រួយបារម្ភរបស់សាធារណៈជន។ ការប្រតិបត្តិតាមបទវិន័យ និងក្រមសីលធមិ ជាពិសេសតាមបទដ្ឋានអន្តរជាតិដោយមន្ត្រីសាធារណៈ រួមទាំងមន្ត្រីប្រតិបត្តិច្បាប់មណ្ឌលកែប្រែ សុខាភិបាល សង្គមកិច្ច និងយោធិន ព្រមទាំងបុគ្គលិកនៃសហគ្រាសសេដ្ឋកិច្ចផង។
- ការហាមឃាត់ដល់ការអនុវត្តន៍ និងនីតិវិធីដែលនាំឱ្យមានការរំលោភបំពាន ដូចជាទីកន្លែងឃុំឃាំងសំងាត់ និងទីកន្លែងឃុំខ្លួនដែលមិនអាចទាក់ទងជាមួយអ្នកខាងក្រៅបាន។

- សហប្រតិបត្តិការជាមួយរដ្ឋដទៃទៀត តាមរយៈការជួយគ្នាទៅវិញទៅមកខាងផ្នែករដ្ឋបាល ឬតុលាការ លើវិស័យដូចជាការស្វែងរកចាប់ខ្លួន ការតាមរកជនល្មើស ការធ្វើបត្យាប័ន និងការរឹបអូសទ្រព្យ ដើម្បីប្រើប្រាស់ជាសំណងដល់ជនរងគ្រោះ ។

ដោយគិតដល់ហេតុការណ៍សោកនាដកម្មនៅប្រទេសមួយចំនួន ដូចជា **រ្វ៉ាន់ដា** និង **បូស្នីអែកហេហ្សហ្គូវិន** សហគមន៍អន្តរជាតិបានខិតខំប្រឹងប្រែងទ្វេដង ដើម្បីធានាថា ជនល្មើសនៃការរំលោភបំពានច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិ មិនអាចគេចផុតពីយុត្តិធម៌ និងនីទណ្ឌភាពបានឡើយ ។ ការយកចិត្តទុកដាក់ជាបឋមត្រូវបានពង្រឹង ទៅលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីធានាថា ជនរងគ្រោះដោយការរំលោភបំពាន ត្រូវទទួលបាននូវការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងតាមទំរង់ខ្លះ នៃការជួសជុលសំណងព្យសនកម្ម ។

នៅឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពី

សិទ្ធិទទួលបានការដោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះដោយការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ គោលការណ៍ជាមូលដ្ឋានទាំងនេះ ធ្វើឱ្យជនរងគ្រោះ អ្នករួចផុតពីស្លាប់ និងអ្នកជំនាន់ក្រោយ មានជំនឿចិត្តដោយធានាពីសិទ្ធិរបស់ជនរងគ្រោះ ដើម្បីទទួលបានប្រយោជន៍ពីការដោះស្រាយនានា និងការជួសជុលសំណងព្យសនកម្មតាមមធ្យោបាយមួយពេញលេញ និងមានលក្ខណៈជាប្រព័ន្ធ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់អន្តរជាតិ។

គោលការណ៍ជាមូលដ្ឋាននេះមិនបង្កើតកាតព្វកិច្ចថ្មីតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិឡើយ ប៉ុន្តែកំណត់ពីមធ្យោបាយនានាឱ្យរដ្ឋទាំងឡាយ អនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់ជាធរមានរបស់ខ្លួន អនុលោមតាមច្បាប់អន្តរជាតិ។ គោលការណ៍ទាំងនេះ សំដៅអនុវត្តចំពោះការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបង្កើតឱ្យមានការមិនគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សតាមចរិតធ្ងន់ធ្ងរបំផុតនៃការរំលោភបំពានទាំងនេះ។

គោលការណ៍ជាមូលដ្ឋាននេះ គួសបញ្ជាក់ជាថ្មី **ពីកាតព្វកិច្ចគោរព កាតព្វកិច្ចធានាការគោរព និងកាតព្វកិច្ចអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង ច្បាប់មនុស្សធម៌អន្តរជាតិ** របស់រដ្ឋនីមួយៗ ឱ្យស្របតាមកាតព្វកិច្ចសន្ធិសញ្ញា ច្បាប់ទំលាប់អន្តរជាតិ និង ច្បាប់ជាតិ។ អាស្រ័យហេតុនេះ រដ្ឋទាំងឡាយ ត្រូវបានតំរូវឱ្យអនុម័តច្បាប់នានាស្របតាមបទដ្ឋានអន្តរជាតិ ហើយមានតួនាទីៈ

- **ទប់ស្កាត់**ការរំលោភបំពាន ។
- **ស៊ើបអង្កេត**ការរំលោភបំពាន អោយបានប្រសិទ្ធភាព ឆាប់រហ័ស ទាំងស្រុង និងមិនលំអៀង ហើយ**ធ្វើការផ្តន្ទាទោសជនល្មើស** ។
- ផ្តល់ដល់ជនរងគ្រោះ **នូវសិទ្ធិទទួលបានយុត្តិធម៌ស្មើភាពគ្នា និងមានប្រសិទ្ធភាព** និង
- ផ្តល់**ការដោះស្រាយដ៏មានប្រសិទ្ធភាព** រួមទាំងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះ។

គោលការណ៍ជាមូលដ្ឋាននេះ តំរូវឱ្យរដ្ឋទាំងឡាយ

**សហការគ្នា**ទៅវិញទៅមក និងជួយដល់ស្ថាប័នតុលាការអន្តរជាតិ ក្នុងការផ្តន្ទាទោសការរំលោភបំពានទាំងនេះដែលបង្កើតជាឧក្រិដ្ឋកម្ម អន្តរជាតិ ហើយតំរូវឱ្យរដ្ឋទាំងឡាយ អនុម័តវិធានការនានា ដើម្បី សំរួលដល់ការផ្តន្ទាទោសបែបនេះ តាមរយៈការបង្កើត**យុត្តាធិការ សកល** និងកិច្ចព្រមព្រៀង**បត្យាប័ន**។

**គោលការណ៍ជាមូលដ្ឋាន**នេះ អះអាងថាការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ **គ្មានអាជ្ញាយុកាល** ទេ។

**គោលការណ៍ជាមូលដ្ឋាន**នេះអនុម័តទស្សនៈវិស័យមួយ ដោយទុកជនរងគ្រោះថា ជាអ្នកដែលត្រូវយកចិត្តទុកដាក់បំផុត ។ បន្ទាប់ពីឱ្យនិយមន័យនៃពាក្យជនរងគ្រោះ គោលការណ៍នេះអះអាងថា **ជនរងគ្រោះ គួរត្រូវបានប្រព្រឹត្តលើដោយមនុស្សធម៌ និង ដោយគោរព ចំពោះសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សរបស់ពួកគេ** ហើយគួរទទួលបាននូវ**ការការពារ**ដ៏សមស្រប។

សិទ្ធិជនរងគ្រោះទទួលបានការដោះស្រាយ រួមមានធាតុ

ផ្សំដូចខាងក្រោម៖

*សិទ្ធិទទួលបានយុត្តិធម៌ស្មើភាពគ្នា និងមានប្រសិទ្ធភាព៖*

ជនរងគ្រោះ ត្រូវមានសិទ្ធិទទួលបានស្មើភាពគ្នា នូវការដោះស្រាយតាមផ្លូវតុលាការមួយ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងការដោះស្រាយផ្សេងៗទៀតដែលមានចែងដូចក្នុងច្បាប់ជាតិនិងអន្តរជាតិ។ រដ្ឋទាំងឡាយ មានកាតព្វកិច្ចធានាថា ជនរងគ្រោះមានសិទ្ធិទទួលបានព័ត៌មាន ពីការដោះស្រាយទាំងនេះ ដែលមានចំពោះពួកគេ ជួយជនរងគ្រោះក្នុងការស្វែងរកការដោះស្រាយទាំងនេះ និងធានាថាពួកគេ និងក្រុមគ្រួសារពួកគេ ព្រមទាំងសាក្សី ត្រូវបានទទួលការការពារគ្រប់គ្រាន់ ទាំងមុនពេល កំឡុងពេល និងក្រោយពេលចំណាត់ការរឿងក្តីនីមួយៗ។

ត្រូវទទួលស្គាល់ដែរថា ក្រុម ឬបុគ្គលទាំងឡាយ អាចជាគោលដៅក្នុងការរំលោភបំពាន ហើយមានសិទ្ធិស្វែងរកការជួសជុលសំណងព្យសនកម្មជាក្រុមបាន។

*ការជួសជុលសំណងព្យសនកម្ម អោយបានគ្រប់គ្រាន់ មានប្រសិទ្ធភាព និងឆាប់រហ័ស ចំពោះអន្តរាយដែលទទួលរង ៖*

**គោលការណ៍ជាមូលដ្ឋាននេះ** ចែងយ៉ាងពិស្តារ ពីវិធីដែលជនរងគ្រោះ គួរទទួលបានការជួសជុលសំណងព្យសនកម្មឱ្យបានគ្រប់គ្រាន់ មានប្រសិទ្ធភាព និងឆាប់រហ័ស តាមសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងអន្តរាយដែលទទួលរង។ ការជួសជុលសំណងព្យសនកម្ម ឱ្យបានពេញលេញ និងមានប្រសិទ្ធភាព អាចអនុវត្តបាន តាមទំរង់ណាមួយដូចខាងក្រោមនេះ

*បដិទានៈ* ប្រសិនជាអាច សំដៅដល់ការស្តារជនរងគ្រោះឱ្យវិលទៅកាន់ស្ថានភាពដើមរបស់គេឡើងវិញ ដូចកាលពីមុនការរំលោភបំពានកើតឡើង។

*សំណងជាប្រាក់ៈ* សំដៅដល់ការខូចខាតដែលអាចវាយតំលៃជាប្រាក់បានដូចជាអន្តរាយផ្លូវកាយ ឬផ្លូវចិត្ត ការបាត់បង់ឱកាស ការខូចខាតសំភារៈ ព្រមទាំងការខូចខាតខាងសីលធម៌ និងតំលៃ។

*ការស្តារនីតិសម្បទាៈ* រួមមានការថែរក្សាតាមវេជ្ជសាស្ត្រ និងតាមចិត្តសាស្ត្រ ព្រមទាំងសេវាកម្មច្បាប់ និងសង្គមកិច្ច។

*ការធ្វើឱ្យពេញចិត្តៈ* រួមមាន វិធានការបញ្ឈប់មិនអោយមានការរំលោភបំពាន ធ្វើការកែតំរូវ និងបង្ហាញជាសាធារណៈពីហេតុការណ៍

ស្វែងរកជនដែលបាត់ខ្លួន និងធ្វើការគាស់សាកសព ព្រមទាំងធ្វើការផ្តន្ទាទោសទាំងតាមផ្លូវរដ្ឋបាល ទាំងតាមផ្លូវតុលាការដល់ជនល្មើស។ *ការធ្វើអោយពេញចិត្ត*ក៏អាចអនុវត្តផងដែរ តាមទំរង់នៃការសុំទោសជាសាធារណៈ ការស្តារនីតិសម្បទាជាផ្លូវការ ដល់កិត្តិយសដែលត្រូវខូចខាត ការធ្វើបុណ្យរំលឹកខួប និងការគោរពវិញ្ញាណក្ខន្ធ និងការដាក់បញ្ចូលដំណើររឿងពិតទៅក្នុងកម្មវិធីអប់រំ។

បន្ថែមពីនេះទៅទៀត រដ្ឋទាំងឡាយគួរផ្តល់ *ការធានាមិនឱ្យការរំលោភបំពានកើតមានជាថ្មី* រួមទាំងវិធានការជាក់ស្តែង ដើម្បីទប់ស្កាត់ការរំលោភបំពានទាំងនេះ មិនអោយកើតឡើងជាថ្មីម្តងទៀត។ វិធានការនានាដែលត្រូវស្នើឡើង បង្កើតបានជាកម្មវិធីរួមមួយរបស់រដ្ឋាភិបាល សំរាប់ពង្រឹងដល់ការការពារសិទ្ធិមនុស្ស ក្រោមដំបូលនីតិរដ្ឋ ហើយរួមមានៈ

- ធានាឱ្យមានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព នៃភាពស៊ីវិលទៅលើកងទ័ព និងកំលាំងសន្តិសុខ។
- ធានាឱ្យមាននីតិវិធីត្រឹមត្រូវ ភាពយុត្តិធម៌ និងភាពមិនលំអៀងនៅគ្រប់ចំណាត់ការតាមបែបស៊ីវិល និងយោធា។

- ពង្រឹងឯករាជ្យភាពរបស់តុលាការ ។
- ការពារមេធាវី វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា អ្នកកាសែត ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស ។
- ផ្តល់ការអប់រំអំពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌បន្ថែមទៀត ជាពិសេសដល់មន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីយោធា ។
- លើកស្ទួយក្រមសីលធម៌ និងបទវិន័យ សំរាប់មន្ត្រីសាធារណៈ ទាំងអស់ ។
- ទប់ស្កាត់ និងតាមឃ្លាំមើលជំលោះជាលក្ខណៈសង្គម ។
- កែទម្រង់ច្បាប់ទាំងឡាយណាដែលរួមចំណែក ដល់ការរំលោភបំពាន ។

## *សិទ្ធិទទួលបានព័ត៌មានដែលពាក់ព័ន្ធស្តីពីការរំលោភបំពាន និងយន្តការជួសជុលសំណងព្យសនកម្ម*

រដ្ឋទាំងឡាយគួរធានាថា ជនរងគ្រោះ និងសាធារណៈជនទូទៅ ជ្រាបពីសិទ្ធិ និងការដោះស្រាយទាំងឡាយ ដែលមានចែងនៅក្នុង **គោលការណ៍ជាមូលដ្ឋាននេះ** ហើយជនរងគ្រោះ គួរតែអាច

ទទួលបានព័ត៌ មានថា ហេតុអ្វីបានជាគេត្រូវក្លាយជាជនរងគ្រោះ។

## ការដោះស្រាយនានាចំពោះការរំលោភបំពាននៅកម្ពុជា

ក្នុងកំឡុងជម្លោះនៅកម្ពុជា និងជាពិសេស ក្នុងរយៈពេលគ្រប់គ្រងដោយខ្មែរក្រហម ប្រជាជនកម្ពុជាបានទទួលរងការរំលោភបំពានសិទ្ធិមនុស្សដ៏កំរោល នៅពេលដែលបទដ្ឋានមនុស្សធម៌មិនជាមូលដ្ឋាន មិនត្រូវបានគេយកចិត្តទុកដាក់ ជាមួយនឹងបញ្ហានីទណ្ឌភាព។ ដើម្បីថ្លែងពីការរំលោភបំពានទាំងនេះនិងផ្ដល់ឱ្យជនរងគ្រោះនៃរបបខ្មែរក្រហមនូវការដោះស្រាយតាមទំរង់ខ្លះ ចំពោះការឈឺចាប់របស់ពួកគេ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានព្រមព្រៀងគ្នាក្នុងឆ្នាំ២០០៣ រៀបចំអោយមានសវនាការ នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដើម្បីនាំយកមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានទាំងនេះ មកតុលា-ការ។ បន្ទាប់ពីមានការពន្យាពេលជាច្រើន អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានចាប់ផ្ដើមនីតិវិធីរបស់ខ្លួនកាលពីខែកក្កដាឆ្នាំ២០០៧។

វិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការ

កម្ពុជា ផ្តល់ឱ្យជនរងគ្រោះ ដើរតួនាទីកណ្តាលមួយ នៅក្នុងនីតិវិធីៈ អនុលោមតាមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជនរងគ្រោះ អាចចូលរួមក្នុងនីតិវិធី ជាភាគីរដ្ឋប្បវេណីផ្លូវការ ហើយអាចមានសិទ្ធិទាមទារសំណងតាមទំរង់ខ្លះ។ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានបង្កើតអង្គភាពគាំទ្រជនរងគ្រោះ ដើម្បីជួយជនរងគ្រោះឱ្យចូលរួមក្នុងដំណើរការក្តី។

ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា នឹងផ្តល់តាមលទ្ធភាពខ្ពស់បំផុតត្រឹមការដោះស្រាយមួយផ្នែកប៉ុណ្ណោះ ដល់ជនរងគ្រោះពីជម្លោះនៅកម្ពុជា។ ការដោះស្រាយដែលល្អបំផុត និងមានប្រសិទ្ធភាពបំផុត គឺត្រូវធានាថា ការរំលោភបំពានច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិមិនអាចកើតឡើងនៅកម្ពុជា នាសម័យកាលនេះទៀតទេ។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១បានទទួលស្គាល់ពីការពិតជាស្នូលនេះ ដោយប្រកាសថា "ប្រវត្តិសាស្ត្រដ៏សោកនាដកម្មថ្មីៗរបស់កម្ពុជា ទាមទារឱ្យមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស និងការមិនវិលត្រឡប់មកវិញ នៃរបបនយោបាយ និងការអនុវត្តន៍ ពីអតីតកាល។" ជាលទ្ធផល រដ្ឋធម្មនុញ្ញកម្ពុជា ត្រូវបានព្រាងឡើង

ដោយមានបញ្ចូល សេចក្ដីថ្លែងការណ៍មួយពីសិទ្ធិមនុស្ស ដែលដាក់បញ្ចូលបទដ្ឋានសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ទៅក្នុងច្បាប់កម្ពុជាដោយផ្ទាល់។

មាត្រា៣៩នៃរដ្ឋធម្មនុញ្ញផ្ដល់សិទ្ធិប្ដឹងបរិហារ និងប្ដឹងទាមទារជួសជុលការខូចខាតដល់ប្រជាពលរដ្ឋ ចំពោះការបំពានច្បាប់ណាមួយ ដោយស្ថាប័នរដ្ឋ ឬដោយមន្ត្រីរបស់ខ្លួន តាមរយៈតុលាការ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចូលជាធរមាននៅឆ្នាំ២00៧ មានចែងបទបញ្ញត្តមួយចំនួន អនុញ្ញាតឱ្យជនរងគ្រោះ ប្ដឹងទាមទារសំណងព្យសនកម្ម ថាជាផ្នែកមួយនៃចំណាត់ការនីតិវិធីព្រហ្មទណ្ឌ (មាត្រា១៣ដល់មាត្រា២៦)។ ក្រមរដ្ឋប្បវេណីដែលបានប្រកាសឱ្យប្រើកាលពីឆ្នាំ២00៧ បង្កើតសិទ្ធិជាមូលដ្ឋាន ដល់ឯកត្តជនដែលសិទ្ធិបុគ្គលរបស់គេត្រូវបានរំលោភ ឬអាចត្រូវបានរំលោភ ដោយៈ(១) មានសិទ្ធិស្នើសុំតុលាការឱ្យបញ្ឈប់ការរំលោភនោះ(មាត្រា១១) (២) មានសិទ្ធិទាមទារឱ្យលុបចោលនូវផលនៃសកម្មភាពរំលោភនោះ ប្រសិនបើមាន(មាត្រា១២) និង(៣) មានសិទ្ធិទាមទារសំណងការខូចខាតចំពោះអន្តរាយដែលបានទទួលរង(មាត្រា១៣)។ សិទ្ធិបុគ្គលត្រូវបាន

កំណត់ន័យនៅក្នុងមាត្រា១០ ថាជាសិទ្ធិដែលពាក់ព័ន្ធដល់បុគ្គល រួមទាំង សិទ្ធិមានជីវិត សេរីភាព សុខភាព និងកិត្តិយស ។ល ។

ចាប់ពីឆ្នាំ១៩៩៣មក ដោយមានការយល់ព្រមយ៉ាងពេញលេញពីរាជរដ្ឋាភិបាលកម្ពុជា ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានរក្សាទុកការិយាល័យមួយនៅកម្ពុជា ជាមួយនឹងអាណត្តិមួយ ដើម្បីជួយរដ្ឋាភិបាល និងសង្គមស៊ីវិលឱ្យធានាពីការការពារ និងការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា អោយមានប្រសិទ្ធភាព ។

*ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស*

*ការិយាល័យប្រចាំនៅកម្ពុជា - ខែកក្កដា ឆ្នាំ២០០៧*

# សេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌
# សំរាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ
តាមសេចក្តីសំរេចលេខ៤០/៣៤ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥

## ក- ជនរងគ្រោះនៃឧក្រិដ្ឋកម្ម

១- "ជនរងគ្រោះ" មានន័យថាជនទាំងឡាយណាទោះជាឯកត្តបុគ្គលក្តី ជាសមូហភាពក្តី បានទទួលរងអន្តរាយ រួមទាំងរបួសស្នាមផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់សតិអារម្មណ៍ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ការខូចខាតយ៉ាងធំនៃសិទ្ធិជាមូលដ្ឋានរបស់ពួកគេតាមរយៈអំពើសកម្មឬអកម្មដែលជាការរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌដែលកំពុងអនុវត្តនៅក្នុងរដ្ឋសមាជិក រួមទាំងច្បាប់ទាំងឡាយដែលហាមប្រាមពីការរំលោភអំណាចដែលមានចរិកព្រហ្មទណ្ឌ។

២- តាមសេចក្តីប្រកាសនេះ មនុស្សម្នាក់ អាចចាត់ថាជាជនរងគ្រោះម្នាក់ ដោយមិនគិតថា ជនល្មើសត្រូវបានបង្ហាញអត្តសញ្ញាណ ចាប់ខ្លួន ចោទប្រកាន់ ឬផ្តន្ទាទោសទេ និងដោយមិនគិតពីទំនាក់ទំនងគ្រួសាររវាងជនល្មើស និងជនរងគ្រោះក៏ទេដែរ។ ពាក្យ

ថា "ជនរងគ្រោះ" ក៏មានរួមបញ្ចូលផងដែរ ប្រសិនបើសមស្រប នូវគ្រួសារ ឬសមាជិកគ្រួសារផ្ទាល់របស់ជនរងគ្រោះផ្ទាល់ និងជនទាំងឡាយណាដែលបានទទួលរងអន្តរាយ ដោយសារតែបានអន្តរាគមន៍ជួយជនរងគ្រោះ ដែលទទួលរងការឈឺចាប់ខ្លាំង ឬទប់ស្កាត់មិនឱ្យកើតមានជនរងគ្រោះ។

៣- បទបញ្ញត្តនានា ដែលមាននៅក្នុងសេចក្តីប្រកាសនេះត្រូវយកមកអនុវត្តចំពោះមនុស្សទាំងអស់គ្នាដោយគ្មានការបែងចែកនៃប្រភេទណាមួយ ដូចជាជាតិសាសន៍ ពណ៌សម្បុរ ភេទ អាយុ ភាសាសាសនា សញ្ជាតិ ទស្សនៈនយោបាយ ឬគំនិតផ្សេងទៀត ការអនុវត្តន៍ ឬជំនឿវប្បធម៌ ទ្រព្យសម្បត្តិ ដើមកំណើត ឬឋានៈគ្រួសារ ជាតិពន្ធុ ឬដើមកំណើតសង្គម និងពិការភាពឡើយ។

*សិទ្ធិទទួលបានយុត្តិធម៌ និងការប្រព្រឹត្តមកលើខ្លួនដោយត្រឹមត្រូវ*

៤- ជនរងគ្រោះគួរត្រូវបានគេរាប់រកដោយក្តីមេត្តាករុណា និងដោយក្តីគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ពួកគេ។ ពួកគេមានសិទ្ធិទទួលបានយន្តការនៃយុត្តិធម៌ និងដំណោះស្រាយឆាប់រហ័ស ដូចដែលមានចែងនៅក្នុងច្បាប់ជាតិ ចំពោះអន្តរាយដែលពួកគេបានទទួលរង។

៥-យន្តការរដ្ឋបាល និងតុលាការគួរត្រូវបង្កើតឡើង និងត្រូវពង្រឹង ប្រសិនបើចាំបាច់ ដើម្បីធ្វើឱ្យជនរងគ្រោះទទួលបានការដោះស្រាយ តាមរយៈនីតិវិធីផ្លូវការ និងក្រៅផ្លូវការដែលឆាប់រហ័ស ត្រឹមត្រូវ មិនថ្លៃ និងដែលអាចទទួលយកបាន។ ជនរងគ្រោះគួរត្រូវបានគេប្រាប់ពីសិទ្ធិក្នុងការស្វែងរកដំណោះស្រាយ តាមរយៈយន្តការទាំងនេះ។

៦-ការឆ្លើយតបជាវិជ្ជមាននៃចំណាត់ការតាមផ្លូវតុលាការ និងរដ្ឋបាល ចំពោះសេចក្ដីត្រូវការរបស់ជនរងគ្រោះ គួរតែត្រូវបានសំរួលដោយៈ

ក- ផ្ដល់ព័ត៌មានដល់ជនរងគ្រោះពីតួនាទី និងព្រំដែនរបស់ពួកគេ ពីពេលវេលា និងការវិវត្តន៍នៃចំណាត់ការ ព្រមទាំងសេចក្ដីសំរេចនៃរឿងក្ដីរបស់ពួកគេ ជាពិសេស នៅពេលណាដែលមានពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងនៅពេលណាពួកគេស្នើសុំព័ត៌មានបែបនេះ។

ខ- អនុញ្ញាតឱ្យជនរងគ្រោះ បង្ហាញពីទស្សនៈ និងកង្វល់របស់ពួកគេ ហើយទស្សនៈ និងកង្វល់ទាំងនេះ ត្រូវបានពិចារណានៅដំណាក់ការដ៏សមរម្យនៃចំណាត់ការ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រ-

យោជន៍ផ្ទាល់របស់ពួកគេដោយគ្មានបង្កការខូចខាតដល់ជនជាប់ចោទ និងស្របជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលពាក់ព័ន្ធ ។

គ- ផ្តល់ការជួយគាំទ្រសមស្របដល់ជនរងគ្រោះ នៅគ្រប់ចំណាត់ការតាមផ្លូវច្បាប់ ។

ឃ- ចាត់វិធានការដើម្បីកាត់បន្ថយការលំបាកដល់ជនរងគ្រោះ ការពារជីវិតឯកជនរបស់ពួកគេ នៅពេលណាចាំបាច់ និងធានាសុវត្ថិភាពរបស់ពួកគេ ព្រមទាំងគ្រួសារនិងសាក្សីរបស់ពួកគេពីការបំភិតបំភ័យ និងការសងសឹក ។

ង-បញ្ចៀសការពន្យាពេលដែលមិនចាំបាច់ក្នុងការចេញសាលក្រមនៃរឿងក្តី និងការអនុវត្តន៍សាលក្រម ឬបញ្ជា ឬក្រិត្យដែលចេញឱ្យជាប្រយោជន៍ដល់ជនរងគ្រោះ ។

៧- យន្តការក្រៅផ្លូវការសំរាប់ការដោះស្រាយជំលោះរួមទាំងតាមការសំរុះសំរួល អាជ្ញាកណ្តាល យុត្តិធម៌ប្រពៃណី ឬតាមការអនុវត្តន៍ជាប្រពៃណីរបស់ជនជាតិដើមភាគតិច គួរត្រូវយកមកប្រើប្រាស់តាមការសមស្រប ដើម្បីសំរួលដល់ការផ្សះផ្សារ និងការដោះស្រាយជូនជនរងគ្រោះ ។

## បដិទាន

៨-ជនល្មើស ឬតតិយជនដែលទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ពួកគេ តាមការសមស្របគួរធ្វើបដិទានដល់ជនរងគ្រោះ គ្រួសារ និងសមាជិកគ្រួសារជនរងគ្រោះ។ បដិទានបែបនេះ គួររួមមានការបង្វិលទ្រព្យ ឬចំណាយចំពោះអន្តរាយ ឬការខាតបង់ដែលទទួលរង ការសងលើចំណាយផ្សេងៗ ដែលកើតឡើងដោយសារតែការធ្វើឱ្យក្លាយជាជនរងគ្រោះនេះ ការផ្តល់សេវាកម្ម និងការស្តារឡើងវិញនៃសិទ្ធិ។

៩- រដ្ឋាភិបាលគួរតែពិនិត្យឡើងវិញពីការអនុវត្តន៏ បទបញ្ជា និងច្បាប់របស់ខ្លួន ដើម្បីពិចារណាពីបដិទាននេះ ថាជាជំរើសនៃការផ្តន្ទាទោសមួយ ដែលមាននៅក្នុងរឿងក្តីព្រហ្មទណ្ឌ បន្ថែមទៅលើការផ្តន្ទាទោសព្រហ្មទណ្ឌផ្សេងៗទៀត។

១០-ក្នុងករណីអន្តរាយធ្ងន់ធ្ងរដល់បរិស្ថាន ប្រសិនបើមានបញ្ជាឱ្យធ្វើដូច្នេះ តាមលទ្ធភាពច្រើនបំផុត តាមដែលអាចធ្វើបានបដិទាន គួរតែរួមមាន ការស្តារឡើងវិញនូវបរិស្ថាននោះ កសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញ ការដាក់ជំនួសវិញនូវសម្ភារៈសហគមន៏ និងការសងវិញលើរាល់ការចំណាយដល់ការតាំងទីលំនៅថ្មី នៅពេល

ណាអន្តរាយបែបនេះ បណ្តាលឱ្យមានការផ្លាស់ប្តូរទីតាំងសហគមន៍។

១១-នៅទីណាដែលមន្ត្រីសាធារណៈឬភ្នាក់ងារដទៃទៀត បំពេញមុខងារក្នុងសមត្ថភាពជាមន្ត្រី ឬដូចមន្ត្រី បានរំលោភបំពានច្បាប់ព្រហ្មទណ្ឌជាតិ ជនរងគ្រោះ គួរតែទទួលបានបដិទានពីរដ្ឋដែលមន្ត្រី ឬភ្នាក់ងាររបស់ខ្លួន បានទទួលខុសត្រូវពីអន្តរាយដែលបង្កឡើងនេះ។ ក្នុងករណីដែលអំពើសកម្ម ឬអកម្មបណ្តាលឱ្យមានជនរងគ្រោះ បានកើតឡើងនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលលែងមានអត្ថិភាពតទៅទៀតនោះ រដ្ឋ ឬរដ្ឋាភិបាលដែលទទួលអាណត្តិបន្ត គួរតែទទួលខុសត្រូវផ្តល់បដិទាន ដល់ជនរងគ្រោះ។

## សំណងជាប្រាក់

១២- ប្រសិនបើសំណងជាប្រាក់ មិនត្រូវបានបង់ឱ្យបានពេញលេញ ដោយជនល្មើស ឬដោយប្រភពផ្សេងទៀតនោះ រដ្ឋគួរតែខ្នះខ្នែងផ្តល់សំណងជាប្រាក់ដល់ៈ

ក- ជនរងគ្រោះដែលនៅតែរងរបួសធ្ងន់ធ្ងរលើរាងកាយ ឬខូចខាតសរីរាង្គ ឬសុខភាពផ្លូវចិត្តដែលបណ្តាលមកពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះ។

ខ- គ្រួសារ ជាពិសេស សមាជិកគ្រួសាររបស់ជនដែលបានស្លាប់ ឬ

ក្លាយខ្លួនជាពិការរាងកាយ ឬផ្លូវចិត្តដែលបណ្តាលមកពីការធ្វើអោយក្លាយទៅជាជនរងគ្រោះបែបនេះ។

១៣- គួរតែជំរុញលើកទឹកចិត្តដល់ការបង្កើត ការពង្រឹង និងការពង្រីក មូលនិធិជាតិសំរាប់សំណងដល់ជនរងគ្រោះ។ សំរាប់គោលដៅនេះ មូលនិធិផ្សេងៗទៀត ក៏គួរតែត្រូវបង្កើតឱ្យមានដែរ ប្រសិនបើសមស្រប រួមទាំងក្នុងករណីទាំងឡាយណា ដែលជនរងគ្រោះ គឺជាជនជាតិរបស់រដ្ឋមួយ តែរដ្ឋនោះមិនមានបំណងសងការអន្តរាយដល់ជនរងគ្រោះផង។

## កិច្ចជំនួយសង្គ្រោះ

១៤- ជនរងគ្រោះ គួរទទួលបានកិច្ចជំនួយសង្គ្រោះ ជាសម្ភារៈ ថ្នាំសង្កូវ ផ្លូវចិត្ត និងសង្គមកិច្ចដែលចាំបាច់ តាមរយៈមធ្យោបាយរដ្ឋាភិបាល ការស្ម័គ្រចិត្ត សហគមន៍ដែលមានមូលដ្ឋាននៅទីនោះ និងតាមរយៈមធ្យោបាយជាប្រពៃណី របស់ជនជាតិដើមភាគតិច។

១៥- ជនរងគ្រោះ គួរតែត្រូវបានគេប្រាប់ពីភាពអាចរកបាននៃសេវាសុខភាព និងសង្គមកិច្ច និងកិច្ចជំនួយសង្គ្រោះដទៃទៀត

ដែលពាក់ព័ន្ធ ហើយជនរងគ្រោះ គួរតែត្រូវបានគេប្រាប់ឱ្យត្រៀមខ្លួនជាស្រេចថា មានលទ្ធភាពគ្រប់គ្រាន់ទទួលបានសេវាទាំងនេះ ។

១៦- សេវាកម្មនគរបាល យុត្តិធម៌ សុខាភិបាល សង្គមកិច្ច និងបុគ្គលិកដទៃទៀតដែលពាក់ព័ន្ធគួរតែទទួលបានការបណ្តុះបណ្តាល ដើម្បីបញ្ជ្រាបពួកគេ ពីសេចក្តីត្រូវការរបស់ជនរងគ្រោះ និងគោលការណ៍ណែនាំនានា ដើម្បីធានាឱ្យមានជំនួយត្រឹមត្រូវ និងបន្ទាន់ ។

១៧- ក្នុងការផ្តល់សេវាកម្ម និងកិច្ចជំនួយសង្គ្រោះដល់ជនរងគ្រោះ គួរតែផ្តោតការយកចិត្តទុកដាក់ដល់អ្នកទាំងឡាយណាដែលមានតំរូវការពិសេស ដោយសារតែប្រភេទនៃអន្តរាយដែលទទួលរង ឬដោយសារតែកត្តានានា ដូចបានរៀបរាប់នៅក្នុងវក្យខ័ណ្ឌ ៣ ខាងលើ ។

## B- ជនរងគ្រោះពីការរំលោភអំណាច

១៨- "ជនរងគ្រោះ" មានន័យថាជនទាំងឡាយណា ទោះជាឯកត្តបុគ្គលក្តី ជាសមូហភាពក្តីបានទទួលរងអន្តរាយ រួមទាំងរបួសស្នាមផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់សតិអារម្មណ៍ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ការខូចខាតយ៉ាងធ្ងន់នៃសិទ្ធិជាមូលដ្ឋានរបស់ពួកគេ តាមរយៈអំពើសកម្ម ឬអកម្ម ដែលមិនទាន់បានបង្កើតទៅជាការរំលោភ

បំពានលើច្បាប់ព្រហ្មទណ្ឌជាតិនៅឡើយក្តី តែពិតជាបាន រំលោភបំពានវិធានទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។

១៩- រដ្ឋ គួរពិចារណាដាក់បញ្ចូលទៅក្នុងវិធានច្បាប់ជាតិនូវការហាមប្រាមការរំលោភអំណាច និងផ្តល់ការដោះស្រាយដល់ជនរងគ្រោះពីការរំលោភបែបនេះ ។ ជាពិសេស ការដោះស្រាយបែបនេះគួរតែបញ្ចូលបដិទាននិង/ឬសំណងជាប្រាក់ និងកិច្ចជំនួយសង្គ្រោះនិងការគាំទ្រផ្នែកសម្ភារៈ ថ្នាំសង្កូវ ផ្លូវចិត្ត និងសង្គមកិច្ចដែលចាំបាច់ ។

២០- រដ្ឋគួរពិចារណា ចរចាពីសន្ធិសញ្ញាអន្តរជាតិពហុភាគីដែលទាក់ទងដល់ជនរងគ្រោះដូចដែលបានឱ្យនិយមន័យក្នុងវក្យខ័ណ្ឌ ១៨ ។

២១- រដ្ឋគួរពិនិត្យការអនុវត្តន៍ និងច្បាប់ដែលនៅជាធរមានរបស់ខ្លួនឱ្យបានទៀងទាត់ ដើម្បីធានាថា ការឆ្លើយតបជាវិជ្ជមានរបស់ខ្លួនចំពោះកាលៈទេសៈប្រែប្រួល ប្រសិនបើចាំបាច់ គួរតែអនុម័ត និងអនុវត្តច្បាប់ហាមប្រាមអំពើនានា ដែលបង្កើតទៅជាការរំលោភអំណាចនយោបាយ និងសេដ្ឋកិច្ចធ្ងន់ធ្ងរ ព្រមទាំងលើកស្ទួយគោលនយោបាយនិងយន្តការសំរាប់ការទប់ស្កាត់អំពើបែបនេះ ហើយ

គួរតែបង្កើត និងធ្វើឱ្យមានរួចជាស្រេចនូវសិទ្ធិ និងការដោះស្រាយសមស្របនានាដល់ជនរងគ្រោះពីអំពើបែបនេះ។

# គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ ស្តីពីសិទ្ធិទទួលបានការដោះស្រាយ និង ការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះ ដោយការរំលោភបំពានជាំអំពេលលើ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង ការរំលោភបំពានដ៏ធ្ងន់ធ្ងរលើ ច្បាប់មនុស្សធម៌អន្តរជាតិ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ

តាមសេចក្តីសំរេចលេខ៦០/១៤៧ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦

## បុព្វកថា

*មហាសន្និបាតអង្គការសហប្រជាជាតិ*

*ដោយរំលឹកឡើងវិញអំពី* បទបញ្ញត្តិទាំងឡាយដែលផ្តល់សិទ្ធិទទួលបានការដោះស្រាយដល់ជនរងគ្រោះ ដោយការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលមានចែងក្នុងលិខិតុបករណ៍អន្តរជាតិជាច្រើន ជាពិសេស មាត្រា៨នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពល

រដ្ឋ និងសិទ្ធិនយោបាយ មាត្រា៦នៃអនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា១៤នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ឬបន្ថោកបន្ទាប និងមាត្រា៣៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ហើយនិងការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ដូចមានចែងក្នុងមាត្រា៣ នៃអនុសញ្ញាទីក្រុងឡាអេស្តីពីទំលាប់ និងច្បាប់សង្គ្រាមជើងគោក ចុះថ្ងៃទី១៨-តុលា-១៩០៧(អនុសញ្ញាទី៤) មាត្រា៩១ នៃពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃ១២-សីហា-១៩៤៩ និងស្តីពីការការពារជនរងគ្រោះក្នុងជំលោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារទី១)ចុះថ្ងៃ៨-មិថុនា-១៩៧៧ ព្រមទាំងមាត្រា៦៨ និងមាត្រា៧៥ នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

*ដោយរំលឹកឡើងវិញអំពី* បទបញ្ញត្តិទាំងឡាយដែលផ្តល់សិទ្ធិទទួលបានការដោះស្រាយដល់ជនរងគ្រោះ ដោយការរំលោភបំពានលើសិទ្ធិមនុស្សអន្តរជាតិ ដែលមានចែងក្នុងអនុសញ្ញាថ្នាក់តំបន់នានា ជាពិសេសមាត្រា៧នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន មាត្រា២៥ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងមាត្រា១៣ នៃអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

*ដោយរំលឹកឡើងវិញអំពី* **សេចក្ដីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច** ដែលជាលទ្ធផលនៃការជជែកពិភាក្សាគ្នា ក្នុងសមាជអង្គការសហប្រជាជាតិលើកទីប្រាំពីរ ស្ដីពី ការបង្ការឧក្រិដ្ឋកម្ម និងប្រព្រឹត្តកម្មទៅលើជនល្មើស និងសេចក្ដីសំរេចមហាសន្និបាតលេខ៤០/៣៤ចុះថ្ងៃទី២៩-វិច្ឆិកា-១៩៨៥ដែលតាមរយៈនេះមហាសន្និបាតបានអនុម័តយកអត្ថបទនេះ តាមអនុសាសន៍របស់សមាជ។

*ដោយបញ្ជាក់ជាថ្មីអំពី* គោលការណ៍ដែលបានចែងយ៉ាងច្បាស់ក្នុង **សេចក្ដីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និង ការរំលោភអំណាច** ដោយរួមទាំង គោលការណ៍ដែលថា ជនរងគ្រោះគួរតែត្រូវបានគេប្រព្រឹត្តមកលើខ្លួនដោយក្ដីអាណិតអាសូរ និងគោរពចំពោះសេចក្ដីថ្លៃថ្នូររបស់ពួកគេ គោរពយ៉ាងពេញលេញ នូវសិទ្ធិជនរងគ្រោះក្នុងការប្រើប្រាស់យន្ដការស្វែងរកយុត្តិធម៌ និងយន្ដការជួសជុលការខូចខាត ព្រមទាំងគោលការណ៍ដែលថា ត្រូវជំរុញលើកទឹកចិត្តឱ្យមានការបង្កើត ការពង្រឹង និងការពង្រីកមូលនិធិជាតិសំរាប់ជួសជុលសំណង

ដល់ជនរងគ្រោះ រួមទាំងការបង្កើតឱ្យបានឆាប់រហ័សនូវសិទ្ធិ និងការដោះស្រាយសមស្របដល់ជនរងគ្រោះ។

*ដោយកត់សំគាល់ថា* **លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ**តម្រូវឱ្យមានការបង្កើត "គោលការណ៍ស្តីពីការជួសជុលសំណងព្យសនកម្មដល់ ឬចំពោះជនរងគ្រោះ រួមទាំងបដិទានសំណងជាប្រាក់ និងការស្តារនីតិសម្បទា" តម្រូវឱ្យរដ្ឋសភានៃរដ្ឋភាគីបង្កើតមូលនិធិទំនុកចិត្តមួយ សំរាប់ជាប្រយោជន៍ដល់ជនរងគ្រោះដោយឧក្រិដ្ឋកម្មដែលស្ថិតក្នុងដែនយុត្តាធិការរបស់តុលាការនេះ និងសំរាប់ជាប្រយោជន៏ដល់ក្រុមគ្រួសារជនរងគ្រោះ ហើយផ្តល់អាណត្តិដល់តុលាការនេះឱ្យ "ការពារសុវត្ថិភាព សុខមាលភាពផ្លូវចិត្ត និងផ្លូវកាយ សេចក្តីថ្លៃថ្នូរនិងសិទ្ធិឯកជនរបស់ជនរងគ្រោះ" ហើយអនុញ្ញាតឱ្យជនរងគ្រោះ ចូលរួមនៅគ្រប់ "ដំណាក់ការនៃនីតិវិធីដែលតុលាការយល់ថា ជាការសមស្រប។"

*ដោយបញ្ជាក់ថា* **គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**ដែលមានចែងក្នុងឯកសារនេះសំដៅអនុវត្តចំពោះការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបង្កើតឱ្យមានការ

មិនគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស តាមចរិតធ្ងន់ធ្ងរបំផុតនៃការរំលោភបំពានទាំងនេះ ។

*ដោយសង្កត់ធ្ងន់ថា* **គោលការណ៍ជាមូលដ្ឋាននិងគោលការណ៍ណែនាំ** ដែលមានចែងក្នុងឯកសារនេះ មិនបង្កើតកាតព្វកិច្ចថ្មីតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិឡើយ ប៉ុន្តែកំណត់អំពីយន្តការ បែបបទ នីតិវិធី និងវិធីសាស្ត្រនានាក្នុងការអនុវត្តន៍កាតព្វកិច្ចតាមផ្លូវច្បាប់ជាធរមាន អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិដែលជាការបំពេញបន្ថែម បើទោះជាបទដ្ឋាននៃច្បាប់អន្តរជាតិទាំងពីរនេះ មានលក្ខណៈខុសៗគ្នាក៏ដោយ ។

*ដោយរំលឹកឡើងវិញថា* ច្បាប់អន្តរជាតិមានកាតព្វកិច្ចផ្តន្ទាទោសអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួន ស្របតាមកាតព្វកិច្ចជាអន្តរជាតិរបស់រដ្ឋភាគី និងការទាមទាររបស់ច្បាប់ជាតិ ឬដូចមានចែងក្នុងលក្ខន្តិកៈ ដែលកំពុងអនុវត្តនៅស្ថាប័នតុលាការអន្តរជាតិនានា ហើយថាភារកិច្ចផ្តន្ទាទោសនេះ ពង្រឹងកាតព្វកិច្ចច្បាប់អន្តរជាតិដែលត្រូវអនុវត្តស្របតាមការទាមទារ និងនីតិវិធីច្បាប់ជាតិ និងគាំទ្រដល់ទស្សនៈនៃការបំពេញបន្ថែម ។

*ដោយកត់សំគាល់ថា* ទន្ទឹមនឹងមានទិសដៅជាសំខាន់

ប្រឆាំងនឹងបុគ្គល ទម្រង់បែបថ្មីនៃការធ្វើទុក្ខបុកម្នេញ ក៏អាចមានទិសដៅប្រឆាំងផងដែរនឹងក្រុមមនុស្សដែលជាមុខសញ្ញារួម ។

*ដោយទទួលស្គាល់ថា* ទន្ទឹមនឹងការគោរពសិទ្ធិជនរងគ្រោះក្នុងការទទួលបានប្រយោជន៍ពីការដោះស្រាយនិងការជួសជុលសំណងព្យសនកម្ម សហគមន៍អន្តរជាតិជឿជាក់លើស្ថានភាពដ៏លំបាករបស់ជនរងគ្រោះ អ្នកដែលរួចពីស្លាប់ និងមនុស្សជំនាន់ក្រោយ ហើយបញ្ជាក់ជាថ្មី អំពីគោលការណ៍ច្បាប់អន្តរជាតិ នៃការទទួលខុសត្រូវយុត្តិធម៌ និងនីតិរដ្ឋ ។

*ដោយជឿជាក់ថា* ក្នុងការអនុម័តយកទស្សនវិស័យមួយដែលគិតគូរអំពីជនរងគ្រោះ សហគមន៍អន្តរជាតិត្រូវបញ្ជាក់ពីសាមគ្គីភាពជាមនុស្សរបស់ខ្លួន ជាមួយជនរងគ្រោះដោយការរំលោភបំពានច្បាប់អន្តរជាតិ រួមទាំងការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ព្រមទាំង សាមគ្គីភាពជាមួយមនុស្សជាតិទូទៅ ស្របតាម**គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**ដូចខាងក្រោមនេះ ។

*អនុម័ត* **គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**ដូចខាងក្រោមនេះ ៖

## I- កាតព្វកិច្ចគោរព កាតព្វកិច្ចធានាការគោរព និងកាតព្វកិច្ចអនុវត្ត ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ

១- កាតព្វកិច្ចគោរព ធានាការគោរព និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដូចមានចែងក្នុងអត្ថបទច្បាប់នីមួយៗ មានប្រភពមកពី ៖

(ក) សន្ធិសញ្ញានានា ដែលរដ្ឋមួយគឺជាភាគីមួយ

(ខ) ច្បាប់ទំនៀមទំលាប់អន្តរជាតិ

(គ) ច្បាប់ជាតិរបស់រដ្ឋនីមួយៗ។

២- ប្រសិនជារដ្ឋណាមួយ មិនទាន់បានអនុវត្តដូចនេះ ដូចដែលបានតម្រូវឱ្យតាមច្បាប់អន្តរជាតិ រដ្ឋនោះត្រូវធានាថា ច្បាប់ជាតិរបស់ខ្លួន ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន តាមរយៈ ៖

(ក) ការដាក់បញ្ចូលបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិទៅក្នុងច្បាប់ជាតិរបស់ខ្លួន ឬបើពុំនោះទេ ត្រូវអនុវត្តបទដ្ឋានទាំងនេះនៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនតែម្តង ។

(ខ) ការអនុម័តនីតិវិធីរដ្ឋបាល និងនីតិវិធីច្បាប់សមស្រប និងមានប្រសិទ្ធភាព ព្រមទាំងវិធានការសមស្របដទៃទៀត ដែលផ្តល់

សិទ្ធិឱ្យស្វែងរកយុត្តិធម៌ប្រកបដោយភាពត្រឹមត្រូវ ឆាប់រហ័ស និងមានប្រសិទ្ធភាព ។

(គ) ការដោះស្រាយអោយបានពេញលេញ ឆាប់រហ័ស សមស្រប និងមានប្រសិទ្ធភាព រួមទាំងការជួសជុលសំណងព្យសនកម្ម ដូចបានកំណត់ខាងក្រោម ។

(ឃ) ការធានាថា ច្បាប់ជាតិរបស់ខ្លួនមានចែងយ៉ាងហោចណាស់ក្នុងកំរិតដូចគ្នា អំពីការការពារជនរងគ្រោះ ដូចដែលបានតម្រូវដោយកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ។

## II- វិសាលភាពនៃកាតព្វកិច្ច

៣- កាតព្វកិច្ចគោរព កាតព្វកិច្ចធានាការគោរព និងកាតព្វកិច្ចអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិដូចមានចែងក្នុងអត្ថបទច្បាប់នីមួយៗ ក្នុងនោះរួមមានភារកិច្ច :

(ក) ចាត់វិធានការសមស្របតាមផ្លូវច្បាប់ ផ្លូវរដ្ឋបាល និងវិធានការសមស្របដទៃទៀតដើម្បីទប់ស្កាត់ការរំលោភបំពានផ្សេងៗ

(ខ) ស៊ើបអង្កេតការរំលោភបំពានផ្សេងៗ ប្រកបដោយប្រសិទ្ធភាព ឆាប់រហ័ស ទាំងស្រុងនិងមិនលំអៀង ហើយប្រសិនជាសមស្រប

ត្រូវចាត់វិធានការប្រឆាំងនឹងជនទាំងឡាយណាដែលត្រូវគេចោទប្រ-
កាន់ថាជាអ្នកទទួលខុសត្រូវស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

（គ） ផ្តល់ឱ្យជនទាំងឡាយណាដែលអះអាងថា ជាជនរងគ្រោះ ដោយការរំលោភបំពានច្បាប់សិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌ នូវសិទ្ធិក្នុងការស្វែងរកយុត្តិធម៌ អោយបានស្មើគ្នា និងមានប្រសិទ្ធភាព ដូចបានរៀបរាប់ខាងក្រោម ដោយមិនគិតថានរណាជាអ្នកត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននោះឡើយ ហើយ

（ឃ） ផ្តល់ការដោះស្រាយប្រកបដោយប្រសិទ្ធភាពដល់ជនរង-គ្រោះ រួមទាំងការជួសជុលសំណងព្យសនកម្ម ដូចបានរៀបរាប់ខាងក្រោម ។

## III- ការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដែលបង្កើតជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ

៤-ក្នុងករណីមានការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបង្កើតជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ រដ្ឋមានភារ

កិច្ចធ្វើការស៊ើបអង្កេត ហើយប្រសិនជាមានភស្តុតាងគ្រប់គ្រាន់ រដ្ឋមានភារកិច្ចធ្វើការចោទប្រកាន់ជនដែលគេអះអាងថា ជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពានទាំងនោះ ហើយប្រសិនជារកឃើញថាមានពិរុទ្ធភាព រដ្ឋមានភារកិច្ចផ្ដន្ទាទោសជននោះ ។ លើសពីនេះទៅទៀត នៅក្នុងករណីទាំងនេះ ស្របតាមច្បាប់អន្តរជាតិ រដ្ឋត្រូវសហការជាមួយរដ្ឋមួយផ្សេងទៀត ហើយជួយដល់ស្ថាប័នតុលាការអន្តរជាតិដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត និងការផ្តន្ទាទោសចំពោះការរំលោភបំពានទាំងនោះ ។

៥- ដើម្បីសំរេចគោលដៅនេះ បើមានបញ្ញត្តិចែងក្នុងសន្ធិសញ្ញាជាធរមាន ឬក្រោមកាតព្វកិច្ចច្បាប់អន្តរជាតិដទៃទៀត រដ្ឋត្រូវដាក់បញ្ចូល ឬពុំនោះទេ ត្រូវអនុវត្តក្នុងក្របខ័ណ្ឌច្បាប់ជាតិរបស់ខ្លួនតែម្តង នូវបទបញ្ញត្តិសមស្របចំពោះយុត្តាធិការសកល ។ ម្យ៉ាងវិញទៀត បើមានបញ្ញត្តិចែងក្នុងសន្ធិសញ្ញាជាធរមាន ឬក្នុងកាតព្វកិច្ចច្បាប់អន្តរជាតិដទៃទៀត រដ្ឋគួរតែសំរួលដល់ការធ្វើបត្យាប័ន ឬប្រគល់ជនល្មើសទៅរដ្ឋផ្សេងទៀត និងទៅស្ថាប័នតុលាការអន្តរជាតិតាមការសមស្រប ហើយត្រូវផ្តល់ជំនួយផ្នែកច្បាប់ និងទម្រង់ផ្សេងទៀតនៃកិច្ចសហប្រតិបត្តិស្របតាមប្រព័ន្ធយុត្តិធមិអន្តរជាតិ ដោយ

រួមទាំងការជួយឧបត្ថម្ភ និងការការពារដល់ជនរងគ្រោះ និងសាក្សី ស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងស្ថិតក្រោមការទាម ទាររបស់ច្បាប់អន្តរជាតិ ដូចជា ការទាមទារទាំងឡាយដែលទាក់ទង នឹងការហាមប្រាមពីការធ្វើទារុណកម្ម និងទំរង់ដទៃទៀតនៃការ ប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោក បន្ទាប ។

## IV- អាជ្ញាយុកាល

៦-ប្រសិនជាមានចែងដូច្នេះ នៅក្នុងសន្ធិសញ្ញាជាធរមាន ឬនៅក្នុងកាតព្វកិច្ចច្បាប់អន្តរជាតិដទៃទៀត អាជ្ញាយុកាល នឹងមិន អនុវត្តចំពោះ ការរំលោភបំពានដ៏កំរោល លើច្បាប់សិទ្ធិមនុស្សអន្តរ ជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដែល បង្កើតជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិឡើយ ។

៧-អាជ្ញាយុកាលនៃច្បាប់ជាតិចំពោះប្រភេទផ្សេងៗទៀត នៃការរំលោភបំពានដែលមិនបង្កើតជាបទឧក្រិដ្ឋ ក្រោមច្បាប់អន្តរ ជាតិ ដោយរួមទាំង អាជ្ញាយុកាលដែលត្រូវអនុវត្តចំពោះបណ្តឹងរដ្ឋ ប្បវេណី និងនីតិវិធីដទៃទៀត មិនគួររិតត្បិតហួសហេតុឡើយ ។

## V- ជនរងគ្រោះដោយការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ

៨- សំរាប់គោលបំណងនៃឯកសារនេះ ជនរងគ្រោះគឺជាបុគ្គលទាំងឡាយដែលជាឯកត្តបុគ្គល ឬជាសមូហភាពទទួលរងនូវការខូចខាត ដោយរួមទាំងរបួសខាងផ្លូវកាយ ឬចិត្ត ការឈឺចាប់ខាងផ្លូវអារម្មណ៍ ការខាតបង់ខាងសេដ្ឋកិច្ច ឬការអន្តរាយជាដុំកំភួនដល់សិទ្ធិជាមូលដ្ឋានរបស់ខ្លួន តាមរយៈអំពើសកម្ម ឬអកម្មដែលបង្កើតជាការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ ប្រសិនបើសមស្រប និងស្របតាមច្បាប់ជាតិ ពាក្យថា "ជនរងគ្រោះ" រាប់បញ្ចូលផងដែរនូវក្រុមគ្រួសារផ្ទាល់ និងអ្នកទាំងឡាយណាដែលនៅក្នុងបន្ទុករបស់ជនរងគ្រោះផ្ទាល់ និងបុគ្គលទាំងឡាយដែលបានទទួលរងការខូចខាតដោយសារតែ ការធ្វើអន្តរាគមន៍ ជួយជនរងគ្រោះដែលកំពុងស្ថិតក្នុងភាពអាសន្ន ឬទប់ស្កាត់មិនឱ្យជននោះក្លាយទៅជាជនរងគ្រោះ។

៩- បុគ្គលម្នាក់ត្រូវបានចាត់ថាជាជនរងគ្រោះ ដោយមិនចាំបាច់គិតថា ទាល់តែជនល្មើស ត្រូវបានរកឃើញ ចាប់ខ្លួន ចោទប្រកាន់ ឬផ្តន្ទាទោសនោះទេ ហើយក៏មិនចាំបាច់គិតពីទំនាក់ទំនងជា

គ្រួសាររវាងជនល្មើស និងជនរងគ្រោះនោះដែរ ។

## VI- ការប្រព្រឹត្តលើជនរងគ្រោះ

១០- ត្រូវប្រព្រឹត្តដោយមនុស្សធម៌ទៅលើជនរងគ្រោះ និងត្រូវគោរពចំពោះសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សរបស់ជនរងគ្រោះ ហើយគួរចាត់វិធានការសមស្រប ដើម្បីធានាសុវត្ថិភាព សុខមាលភាពផ្លូវកាយ និងផ្លូវចិត្ត និងសិទ្ធិឯកជន ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេ។ រដ្ឋគួរធានាថា ច្បាប់ជាតិរបស់ខ្លួន តាមវិសាលភាពដែលអាចធ្វើបាន ត្រូវចែងថា ជនរងគ្រោះដែលបានទទួលរងអំពើហឹង្សា ឬការគ្រាំគ្រាចិត្ត ទទួលបានអត្ថប្រយោជន៍ពីការគិតគូរ និងការគាំពារជាពិសេស ដើម្បីបញ្ចៀស មិនឱ្យកើតមានការគ្រាំគ្រាចិត្តជាថ្មី នៅក្នុងនីតិវិធីច្បាប់ និងនីតិវិធីរដ្ឋបាលដែលតាក់តែងឡើង ដើម្បីផ្តល់យុត្តិធម៌ និងការជួសជុលសំណងព្យសនកម្ម ។

## VII- សិទ្ធិជនរងគ្រោះក្នុងការទទួលបានការដោះស្រាយ

១១- ការដោះស្រាយ ចំពោះការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំងសិទ្ធិខាងក្រោមរបស់ជនរងគ្រោះ ដូច

មានចែងក្នុងច្បាប់អន្តរជាតិ ៖

(ក) សិទ្ធិទទួលបានយុត្តិធម៌ដោយស្មើភាព និងមានប្រសិទ្ធភាព។

(ខ) សិទ្ធិទទួលបាន ការជួសជុលសំណងព្យសនកម្មគ្រប់គ្រាន់ មានប្រសិទ្ធភាព និងឆាប់រហ័សចំពោះអន្តរាយដែលបានទទួលរង។

(គ) សិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធស្តីពីការរំលោភបំពាន និងយន្តការនៃការជួសជុលសំណងព្យសនកម្ម។

## VIII- **សិទ្ធិទទួលបានយុត្តិធម៌**

១២- ជនរងគ្រោះ ដោយការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិឬដោយការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវមានសិទ្ធិស្មើគ្នា ទទួលបានការដោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាពដូចដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ។ ការដោះស្រាយដទៃទៀត ដែលមានចំពោះជនរងគ្រោះរួមមាន សិទ្ធិទទួលបានការប្រើប្រាស់ស្ថាប័នរដ្ឋបាល និងស្ថាប័នផ្សេងទៀត ព្រមទាំងយន្តការ វិធីសាស្ត្រ និងនីតិវិធីដែលត្រូវអនុវត្តស្របតាមច្បាប់ជាតិ ។ កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងច្បាប់អន្តរ

ជាតិ ដើម្បីធានាការពារសិទ្ធិទទួលបានយុត្តិធម៌ ព្រមទាំងនីតិវិធីត្រឹមត្រូវ និងមិនលំអៀង ត្រូវចែងឡើងវិញនៅក្នុងច្បាប់ជាតិ។ ដើម្បីសំរេចគោលដៅនេះ រដ្ឋត្រូវ ៈ

(ក) ធ្វើការផ្សព្វផ្សាយ តាមរយៈយន្តការសាធារណៈ និងឯកជន នូវព័ត៌មានស្តីពីការដោះស្រាយទាំងអស់ ដែលមានចំពោះការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។

(ខ) ចាត់វិធានការដើម្បីកាត់បន្ថយការលំបាកដល់ជនរងគ្រោះ និងតំណាងរបស់ពួកគេ បង្ការការជ្រៀតជ្រែកដោយខុសច្បាប់លើសិទ្ធិឯកជន តាមដែលអាចធ្វើបាន ហើយត្រូវធានាសុវត្ថិភាពពួកគេពីការបំភិតបំភ័យ និងការសងសឹក ព្រមទាំងក្រុមគ្រួសារ និងសាក្សីរបស់ពួកគេ ទាំងនៅមុនពេល នៅក្នុងពេល និងនៅក្រោយពេលដំណើរការនីតិវិធីច្បាប់ នីតិវិធីរដ្ឋបាល ឬនីតិវិធីផ្សេងៗទៀត ដែលប៉ះពាល់ដល់ផលប្រយោជន៏របស់ជនរងគ្រោះ។

(គ) ផ្តល់ការជួយឧបត្ថម្ភសមស្រប ដល់ជនរងគ្រោះដែលស្វែងរកសិទ្ធិទទួលបានយុត្តិធម៌។

(ឃ) ផ្តល់រាល់មធ្យោបាយសមស្របតាមផ្លូវច្បាប់ ការទូត និង កុងស៊ុល ដើម្បីធានាឱ្យជនរងគ្រោះ អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុង ការដោះស្រាយពីការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរ ជាតិ ឬការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ។

១៣- ក្រៅពីសិទ្ធិទទួលបានយុត្តិធម៌ជាបុគ្គល រដ្ឋត្រូវខិត ខំបង្កើតនីតិវិធីផ្សេងៗ ដើម្បីអនុញ្ញាតឱ្យក្រុមជនរងគ្រោះដាក់ពាក្យ បណ្តឹងទាមទារឱ្យជួសជុលសំណងព្យសនកម្ម និងទទួលបានសំណង ព្យសនកម្មនោះសមស្រប ។

១៤- ការដោះស្រាយគ្រប់គ្រាន់ មានប្រសិទ្ធភាព និង ឆាប់រហ័ស ចំពោះការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្ស អន្តរជាតិ ឬការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ គួរបញ្ចូល កិច្ចដំណើរការជាអន្តរជាតិសមស្របទាំងអស់ដែលមាន ដែលតាមរយៈនេះ បុគ្គលម្នាក់ៗអាចមានជំហរផ្លូវច្បាប់ ហើយគួរតែ មិនធ្វើអោយខូចខាត ដល់ការដោះស្រាយនៅថ្នាក់ជាតិណាមួយផ្សេង ទៀតឡើយ ។

## IX- ការជួសជុលសំណងព្យសនកម្មដល់អន្តរាយដែលបានទទួលរង

១៥- ការជួសជុលសំណងព្យសនកម្ម គ្រប់គ្រាន់ មានប្រសិទ្ធភាព និងឆាប់រហ័ស មានគោលដៅលើកស្ទួយយុត្តិធម៌ តាមរយៈការកែតម្រូវ ការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ ការជួសជុលសំណងព្យសនកម្ម គួរតែសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរ នៃការរំលោភបំពាន និងអន្តរាយដែលទទួលរង។ ស្របតាមច្បាប់ជាតិរបស់ខ្លួន និងកាតព្វកិច្ចផ្លូវច្បាប់ជាអន្តរជាតិ រដ្ឋនីមួយៗ ត្រូវផ្តល់សំណងព្យសនកម្មដល់ជនរងគ្រោះចំពោះអំពើសកម្ម ឬអកម្មដែលរដ្ឋអាចជាអ្នកបង្កឡើង ហើយអំពើទាំងនេះអាចបង្កើតជាការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ ក្នុងករណីដែលរូបវន្តបុគ្គលម្នាក់ នីតិបុគ្គលមួយ ឬនីតិបុគ្គលដទៃទៀតត្រូវបានគេរកឃើញថា ជាអ្នកទទួលខុសត្រូវចំពោះការជួសជុលសំណងព្យសនកម្ម ដល់ជនរងគ្រោះណាម្នាក់ ភាគីនោះ ត្រូវតែផ្តល់ការជួសជុលសំណងព្យសនកម្មនោះដល់ជនរងគ្រោះ ឬសងសំណងដល់រដ្ឋវិញ ប្រសិនបើ រដ្ឋបានផ្តល់សំណងព្យសនកម្មដល់ជនរងគ្រោះនោះរួចហើយ។

១៦- រដ្ឋត្រូវខិតខំបង្កើតកម្មវិធីជាតិ សំរាប់ការជួសជុល

សំណងព្យសនកម្ម និងការជួយឧបត្ថម្ភដទៃទៀត ដល់ជនរងគ្រោះ ក្នុងករណីដែលភាគីទាំងឡាយ ដែលទទួលខុសត្រូវចំពោះអន្តរាយ ដែលបានទទួលរង មិនអាច ឬមិនមានឆន្ទៈក្នុងការបំពេញកាតព្វកិច្ច របស់ពួកគេ។

១៧- ចំពោះការទាមទាររបស់ជនរងគ្រោះ រដ្ឋភាគីត្រូវ អនុវត្តសាលក្រមតុលាការជាតិ ដែលសំរេចឱ្យមានការជួសជុល សំណងព្យសនកម្ម ពីរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលខុសត្រូវចំ ពោះអន្តរាយដែលទទួលរង ហើយត្រូវខិតខំអនុវត្តសាលក្រមស្ថាពរ របស់តុលាការបរទេសដែលសំរេចឱ្យមានការជួសជុលសំណងព្យសន កម្ម ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចផ្លូវច្បាប់ជាអន្តរជាតិ។ ដើម្បី សំរេចគោលដៅនេះ រដ្ឋត្រូវចែងនៅក្នុងច្បាប់ជាតិរបស់ខ្លួនពីយន្តការ មានប្រសិទ្ធភាព សំរាប់ការអនុវត្តនីសាលក្រមតុលាការដែលសំរេច ឱ្យមានការជួសជុលសំណងព្យសនកម្ម។

១៨- អនុលោមតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ និង ដោយគិតគូរអំពីកាលៈទេសៈជាបុគ្គល ហើយតាមការសមស្រប និង សមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងកាលៈទេសៈ នៃករណីនីមួយៗ ជនរងគ្រោះដោយការរំលោភបំពានដ៏កំរោល លើ

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង ការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវទទួលបានការជួសជុលសំណងព្យសនកម្មយ៉ាងពេញលេញ និងមានប្រសិទ្ធភាព ដូចមានចែងក្នុងគោលការណ៍ ១៩ និង២៣ដែលរួមទាំងទម្រង់ដូចខាងក្រោមនេះ៖ បដិទាន សំណងជាប្រាក់ ការស្តារនីតិសម្បទា ការធ្វើឱ្យពេញចិត្ត និងការធានាមិនឱ្យការរំលោភបំពាននោះកើតមានជាថ្មី។

១៩- *បដិទាន* ប្រសិនជាអាចធ្វើបាន គួរតែស្តារស្ថានភាពរបស់ជនរងគ្រោះឱ្យដូចជាស្ថានភាពដើម មុនពេលដែលមានការកើតឡើងនៃការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឬការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ តាមការសមស្រប *បដិទាន*រួមមាន៖ការស្តារសេរីភាពឡើងវិញ ការទទួលបានសិទ្ធិមនុស្ស អត្តសញ្ញាណ ជីវភាពរស់នៅ ជួបជុំគ្រួសារ និងសិទ្ធិជាពលរដ្ឋ ការវិលត្រឡប់មកនិវេសនដ្ឋានរបស់ខ្លួនវិញ ការស្តារស្ថានភាពការងារ និងការប្រគល់ឱ្យទ្រព្យសម្បត្តិវិញ។

២០- *សំណងជាប្រាក់* តាមការចាំបាច់ និងសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងកាលៈទេសៈនៃករណីនីមួយៗ គួរផ្តល់ទៅតាមការខូចខាត ដែលអាចវាយតំលៃជាប្រាក់បាន ដែល

បណ្ដាលមកពី ការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិឬការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិដូចជាៈ

(ក) ការខូចខាតខាងផ្លូវកាយ ឬផ្លូវចិត្ត

(ខ) ការបាត់បង់ឱកាស រួមទាំងឱកាសការងារ ឱកាសអប់រំ និងការបាត់បង់អត្ថប្រយោជន៏សង្គម

(គ) ការខូចខាតជាសម្ភារៈ និងការបាត់បង់ប្រាក់ចំណូល រួមទាំងការបាត់បង់សក្ដានុពលខាងប្រាក់ចំណូល

(ឃ) ការខូចខាតខាងសីលធម៌

(ង) ការចំណាយទៅលើជំនួយការច្បាប់ ឬអ្នកជំនាញ សេវាថ្នាំពេទ្យ និងសុខាភិបាល ព្រមទាំងសេវាផ្លូវចិត្ត និងសេវាសង្គមកិច្ច។

២១- *ការស្ដារនីតិសម្បទា* គួររាប់បញ្ចូលការថែទាំផ្នែកវិជ្ជសាស្រ្ដ និងការថែទាំខាងផ្លូវចិត្ត ក៏ដូចជាសេវាច្បាប់ និងសេវាសង្គមកិច្ច។

២២- *ការធ្វើឱ្យពេញចិត្ត* ប្រសិនជាអាចធ្វើបាន គួររាប់បញ្ចូលនូវចំណុចមួយ ឬទាំងអស់ខាងក្រោមនេះ :

(ក) វិធានការមានប្រសិទ្ធភាព ដែលមានគោលដៅបញ្ឈប់ការរំលោភបំពានតទៅទៀត ។

(ខ) ការពិនិត្យផ្ទៀងផ្ទាត់លើអង្គហេតុ និងការលាតត្រដាងពីការពិតជាសាធារណៈ និងទាំងស្រុង ក្នុងករណីដែលការលាតត្រដាងនេះមិនបង្កអន្តរាយ ឬគំរាមកំហែងតទៅទៀតដល់សុវត្ថិភាពនិងផលប្រយោជន៍ជនរងគ្រោះ សាច់ញាតិជនរងគ្រោះ សាក្សី ឬជនទាំងឡាយដែលបានធ្វើអន្តរាគមន៍ជួយជនរងគ្រោះ ឬទប់ស្កាត់មិនឱ្យកើតមានការរំលោភបំពានតទៅទៀត ។

(គ) ការស្វែងរកទីកន្លែងជនបាត់ខ្លួន រកអត្តសញ្ញាណកុមារដែលត្រូវគេចាប់ពង្រត់ និងរកសាកសពជនដែលត្រូវគេសំលាប់ និងការជួយក្នុងរបកគំហើញ ការកំណត់អត្តសញ្ញាណ និងការបញ្ចុះសាកសពឡើងវិញ ស្របតាមបំណងប្រាថ្នាដែលជនរងគ្រោះបានស្នើសុំ ឬសន្មត់ទុក ឬស្របតាមទំនៀមទម្លាប់វប្បធម៌របស់ក្រុមគ្រួសារ និងសហគមន៍ ។

(ឃ) សេចក្តីប្រកាសជាផ្លូវការ ឬសេចក្តីសំរេចរបស់តុលាការក្នុងការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះនិងសិទ្ធិជនរងគ្រោះព្រមទាំងសិទ្ធិរបស់អ្នកដទៃទៀត ដែលមានទំនាក់ទំនងជិតស្និទ្ធជា

មួយជនរងគ្រោះ ។

(ង) ការសុំទោសជាសាធារណៈ ដោយរួមទាំងការទទួលស្គាល់ហេតុការណ៍ពិត និងការព្រមទទួលខុសត្រូវ ។

(ច) ការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់និងរដ្ឋបាលទៅលើជនដែលទទួលខុសត្រូវចំពោះការរំលោភបំពានទាំងនេះ ។

(ឆ) ការធ្វើបុណ្យរំលឹកខួប និងការគោរពវិញ្ញាណក្ខន្ធដល់ជនរងគ្រោះ ។

(ឈ) ការដាក់បញ្ចូលដំណើររឿងពិត អំពីការរំលោភបំពានដែលកើតមាន ទៅក្នុងការបណ្តុះបណ្តាលច្បាប់ សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ និងទៅក្នុងកម្មវិធីអប់រំ នៅគ្រប់ភូមិសិក្សា ។

២៣- *ការធានាមិនឱ្យការរំលោភបំពានកើតមានជាថ្មី* ប្រសិនជាអាចធ្វើបាន គួររាប់បញ្ចូលនូវវិធានការមួយ ឬវិធានការទាំងអស់ខាងក្រោម ដែលនឹងអាចរួមចំណែកផងដែរដល់ការទប់ស្កាត់ ៖

(ក) ធានាឱ្យមានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព នៃភាពស៊ីវិលទៅលើកងទ័ព និងកំលាំងសន្តិសុខ

(ខ) ធានាថារាល់នីតិវិធីស៊ីវិល និងយោធា ត្រូវស្របតាមបទដ្ឋានអន្តរជាតិស្តីពីនីតិវិធីត្រឹមត្រូវ យុត្តិធម៌ និងមិនលំអៀង។

(គ) ពង្រឹងឯករាជ្យភាពរបស់តុលាការ

(ឃ) ការពារបុគ្គលទាំងឡាយដែលមានវិជ្ជាជីវៈច្បាប់ វិជ្ជ-សាស្ត្រ និងគាំពារសុខភាព ការពារវិជ្ជាជីវៈសារព័ត៌មាន និងវិជ្ជាជីវៈពាក់ព័ន្ធដទៃទៀត ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស។

(ង) ផ្តល់ការអប់រំអំពីសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិដល់គ្រប់ផ្នែកទាំងអស់នៃសង្គម និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីប្រតិបត្តិច្បាប់ ព្រមទាំងយោធា និងកំលាំងសន្តិសុខ ដោយឈរលើមូលដ្ឋានអាទិភាព និងនិរន្តរភាព។

(ច) លើកស្ទួយការគោរពក្រមសីលធម៌និងបទវិន័យ ជាពិសេសបទដ្ឋានអន្តរជាតិនានាដោយមន្ត្រីសាធារណៈ រួមទាំងសេវាប្រតិបត្តិច្បាប់ សេវាកែប្រែ សេវាព័ត៌មាន សេវាវិជ្ជសាស្ត្រ សេវាផ្លូវចិត្ត សេវាសង្គមកិច្ច និងយោធិន ព្រមទាំងដោយសហគ្រាសសេដ្ឋកិច្ចនានា។

(ឆ) លើកស្ទួយយន្តការសំរាប់ទប់ស្កាត់ និងតាមឃ្លាំមើលជំ-លោះជាលក្ខណៈសង្គម និងការដោះស្រាយជំលោះទាំងនោះ។

(ជ) ពិនិត្យឡើងវិញ និងកែទម្រង់ច្បាប់ទាំងឡាយណាដែលរួមចំណែកក្នុង ឬដែលអនុញ្ញាតឱ្យមានការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។

## X- សិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងការរំលោភបំពាន និងយន្តការជួសជុលសំណងព្យសនកម្ម

២៤-រដ្ឋទាំងឡាយ គួរបង្កើតមធ្យោបាយផ្តល់ព័ត៌មានដល់សាធារណៈជនទូទៅ ហើយជាពិសេស ដល់ជនរងគ្រោះដោយការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ អំពីសិទ្ធិ និងការដោះស្រាយផ្សេងៗ ដូចដែលមានចែងនៅក្នុង**គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**ទាំងនេះ និងអំពីសេវាច្បាប់ សេវាវេជ្ជសាស្ត្រ សេវាផ្លូវចិត្ត សេវាសង្គម សេវារដ្ឋបាល និងសេវាដទៃផ្សេងទៀតទាំងអស់ដែលមានស្រាប់ ហើយដែលជនរងគ្រោះអាចមានសិទ្ធិទទួលបាន។ ម្យ៉ាងវិញទៀត ជនរងគ្រោះ និងតំណាងរបស់ពួកគេ គួរមានសិទ្ធិស្វែងរក និងទទួលបានព័ត៌មាន អំពីមូលហេតុដែលនាំឱ្យពួកគេក្លាយជាជនរងគ្រោះ និងអំពីមូលហេតុ និងស្ថានភាពទាក់ទងនឹង

ការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ហើយនិងគួរតែមានសិទ្ធិស្វែងយល់អំពីការពិត ដែលទាក់ទិននឹងការរំលោភបំពានទាំងនេះ ។

## XI- **ការមិនរើសអើង**

២៥- ការអនុវត្តន៍ និងការបកស្រាយ **គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**ទាំងនេះ ត្រូវតែស្របជាមួយច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ហើយមិនត្រូវមានការប្រកាន់រើសអើងពីប្រភេទណាមួយ ឬផ្អែកលើមូលហេតុណាមួយ ដោយគ្មានការលើកលែងឡើយ ។

## XII- **ការមិនព្យួរសិទ្ធិ**

២៦- មិនមានបទបញ្ញត្តិណាមួយក្នុង **គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**ទាំងនេះ ត្រូវបានធ្វើការបកស្រាយថាជាការរិតត្បិត ឬជាការព្យួរសិទ្ធិពីសិទ្ធិ ឬកាតព្វកិច្ចណាមួយដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិឡើយ ។ ជាពិសេសត្រូវយល់ថា **គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំ**

ទាំងនេះ មិនប៉ះពាល់ដល់សិទ្ធិក្នុងការដោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះ ដោយការរំលោភបំពានទាំងអស់លើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិឡើយ ។ ត្រូវយល់ថែមទៀតថា**គោលការណ៍ជាមូលដ្ឋាននិងគោលការណ៍ណែនាំ**ទាំងនេះមិនប៉ះពាល់ដល់វិធានពិសេសនានានៃច្បាប់អន្តរជាតិឡើយ ។

## XIII- សិទ្ធិរួមគេដទៃ

២៧- មិនមានបទបញ្ញត្តិណាមួយក្នុងឯកសារនេះត្រូវបានបកស្រាយថា ជាការព្យួរសិទ្ធិអ្នកដទៃទៀត ដែលត្រូវបានការពារដោយច្បាប់ជាតិ ឬច្បាប់អន្តរជាតិឡើយ ជាពិសេសសិទ្ធិរបស់ជនត្រូវចោទដែលត្រូវទទួលបានផលប្រយោជន៍ ពីបទដ្ឋាននៃនីតិវិធីត្រឹមត្រូវដែលអាចអនុវត្តបាន ។